# អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ឆ្នាំ២០១៧ | ប្រទេសកម្ពុជា

INTERNATIONAL BUDGET PARTNERSHIP
IBP

**20** ក្នុងចំណោម 100

**តម្លាភាពថវិកា** (សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា)

ប្រទេសកម្ពុជាផ្តល់ជូនដល់សាធារណៈជននូវព័ត៌មានថវិកា **តិចតួច**

**4** ក្នុងចំណោម 100

**ការចូលរួមរបស់សាធារណៈជន**

ប្រទេសកម្ពុជាផ្តល់ឱកាស**តិចតួច**សម្រាប់សាធារណៈជនចូលរួមក្នុងដំណើរការថវិកា

**55** ក្នុងចំណោម 100

**ការត្រួតពិនិត្យថវិកា**

**ដោយអង្គនីតិបញ្ញត្តិ និងស្ថាប័នសវនកម្មជាន់ខ្ពស់**

ការត្រួតពិនិត្យថវិកាដោយអង្គនីតិបញ្ញត្តិ និងស្ថាប័នសវនកម្មជាន់ខ្ពស់នៅប្រទេសកម្ពុជាគឺ **នៅមានកំរិត**

## តម្លាភាពថវិកា (សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា)

ផ្តោតទៅលើលក្ខណៈវិនិច្ឆ័យ ដែលទទួលស្គាល់ដោយអន្តរជាតិដែលរៀបចំឡើងដោយអង្គការពហុភាគី ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាប្រើប្រាស់សូចនាករចំនួន ១០៩ ដើម្បីវាស់វែងតម្លាភាពថវិកា។ សូចនាករទាំងនេះប៉ាន់ប្រមាណថា តើរដ្ឋាភិបាលផ្សព្វផ្សាយព័ត៌មាននៃឯកសារថវិកាសំខាន់ៗទាំង៨ ជាសាធារណៈបានទាន់ពេលឬទេ និងថាតើទិន្នន័យដែលផ្ទុកក្នុងឯកសារទាំងនោះមានព័ត៌មានគ្រប់គ្រាន់ ព្រមទាំងមានសារៈប្រយោជន៍ប៉ុណ្ណា។

ប្រទេសនីមួយៗ ទទួលបានពិន្ទុណាមួយក្នុងចំណោមពិន្ទុ១០០ ដែលកំណត់ចំណាត់ថ្នាក់របស់ប្រទេសទាំងនោះ នៅក្នុងសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា ដែលជាការសិក្សាឯករាជ្យតែមួយគត់ដែលមានលក្ខណៈប្រៀបធៀបបានជាសកលលើតម្លាភាពថវិកា។

### តើពិន្ទុនៃការផ្សព្វផ្សាយព័ត៌មានថវិកានៃប្រទេសកម្ពុជាមានការវិវឌ្ឍន៍យ៉ាងដូចម្តេច?




### តើតម្លាភាពថវិកានៅកម្ពុជាស្ថិតនៅកំរិតណា ធៀបនឹងប្រទេសដទៃ?




ពិន្ទុនៃប្រទេសកម្ពុជា ២០ លើ១០០ គឺទាបជាងពិន្ទុមធ្យមជាសកល ៤២ លើ ១០០

### ឯកសារថវិកាដែលអាចរកបានជាសាធារណៈសម្រាប់ឆ្នាំ 2008 ដល់ឆ្នាំ 2017

| ឯកសារ | 2008 | 2010 | 2012 | 2015 | 2017 |
|---|---|---|---|---|---|
| របាយការណ៍មុនថវិកា | 🟡 | 🟢 | 🟢 | 🟢 | 🟢 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | 🟡 | 🟡 | 🟡 | 🟡 | 🟡 |
| ថវិកាដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ | 🔴 | 🔴 | 🔴 | 🟡 | 🟢 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🟡 | 🟢 |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 | 🟢 |
| របាយការណ៍បំណាច់ឆ្នាំ | 🟢 | 🟢 | 🟢 | 🔴 | 🟡 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🔴 | 🟢 |

🟢 ផ្សព្វផ្សាយជាសាធារណៈ 🔴 មិនបានផលិត
🟡 ផលិតយឺត ឬសម្រាប់តែប្រើប្រាស់ផ្ទៃក្នុង

### តើប្រទេសកម្ពុជាបានផ្សព្វផ្សាយព័ត៌មាននៃឯកសារថវិកាបានកំរិតណា?



ពិន្ទុនៃប្រទេសកម្ពុជា ២០ នៃសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកានៅឆ្នាំ២០១៧ គឺខ្ពស់ជាងពិន្ទុនៅឆ្នាំ ២០១៥។

តាំងពីឆ្នាំ ២០១៥ ប្រទេសកម្ពុជាបានបង្កើនការផ្សព្វផ្សាយឯកសារថវិកាដូចជា:

- ផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលឆ្នាំ របាយការសវនកម្ម និងរបាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយរបាយការណ៍ក្នុងឆ្នាំទាន់ពេលវេលា

ប្រទេសកម្ពុជាមានភាពខ្វះខាតក្នុងប្រតិបត្តិការណ៍ដូចខាងក្រោម:

- មិនបានផ្សព្វផ្សាយជាសាធារណៈនៅសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល
- បានផលិតរបាយការណ៍បំណាច់ឆ្នាំ ប៉ុន្តែមិនបានធ្វើការផ្សព្វផ្សាយជាសាធារណៈទាន់ពេលវេលា បន្ទាប់ពីការសិក្សា

**ព័ត៌មានលម្អិតនៃឯកសារថវិកាទាំងប្រាំបី**

**របាយការណ៍បុរេថវិកា:** ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីគោលនយោបាយសារពើពន្ធនៃសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ពិពណ៌នាអំពីការព្យាករណ៍នៃសេដ្ឋកិច្ចរបស់រដ្ឋាភិបាលដែលមានដូចជា ប្រាក់ចំណូលដែលរំពឹងទុក ការចំណាយ និងបំណុល។

**សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល:** ផ្ញើសេចក្តីព្រាងច្បាប់ថវិកាទៅអង្គនីតិបញ្ញត្តិដើម្បីស្នើសុំការអនុម័ត ដោយលម្អិតពីប្រភពនៃចំណូល ថវិកាបែងចែកទៅតាមក្រសួង សំណើ ផ្លាស់ប្តូរគោលនយោបាយ និងព័ត៌មានសំខាន់ៗដើម្បីអាចយល់ដឹងអំពីស្ថានភាពសារពើពន្ធប្រទេស។

**ថវិកាដែលបានអនុម័ត:** គឺជាថវិកា ដែលត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ។

**របាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ:** កែច្នៃសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលឱ្យមានភាពសាមញ្ញ និងមិនមានភាពបច្ចេកទេស ដើម្បីសាធារណជនងាយយល់អំពីឯកសារថវិកាសំខាន់ៗ។

**របាយការណ៍ក្នុងឆ្នាំ:** រួមមានឯកសារលើការប្រមូលចំណូលជាក់ស្តែង ការចំណាយជាក់ស្តែង និងបំណុលផ្សេងៗដែលចេញប្រចាំត្រីមាស ឬប្រចាំខែ។

**របាយការណ៍ពាក់កណ្តាលឆ្នាំ:** ធ្វើបច្ចុប្បន្នភាពលើការអនុវត្តថវិកាឱ្យទាន់ពេលវេលា គឺនៅពាក់កណ្តាលឆ្នាំសារពើពន្ធ រួមទាំងការមើលឡើងវិញទៅលើការសន្មត់នៃសេដ្ឋកិច្ច និងការព្យាករណ៍អំពីលទ្ធផលថវិកា។

**របាយការណ៍ដំណាច់ឆ្នាំ:** ពិពណ៌នាអំពីស្ថានភាពនៃគណនីរបស់រាជរដ្ឋាភិបាលនៅចុងឆ្នាំសារពើពន្ធ និងវាយតម្លៃនៃវឌ្ឍនភាពដែលឆ្ពោះទៅសម្រេចបាននូវគោលដៅគោលនយោបាយថវិកា។

**របាយការណ៍សវនកម្ម:** ធ្វើដោយស្ថាប័នសវនកម្មកំពូល ដែលឯកសារនេះពិនិត្យដោយភាពសុក្រិត និងភាពពេញលេញនៃគណនីចុងឆ្នាំរបស់រដ្ឋាភិបាល។

## ការចូលរួមជាសាធារណៈ

តម្លាភាពតែមួយ មិនគ្រប់គ្រាន់សម្រាប់ការពង្រឹងអភិបាលកិច្ចបានទេ ប៉ុន្តែការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកា អាចធ្វើឱ្យមានផលវិជ្ជមានបានកាន់តែប្រសើរឡើង និងធ្វើឱ្យមានតម្លាភាពថវិកាកាន់តែល្អជាងមុន ។

ដើម្បីវាស់វែងទៅលើការចូលរួមជាសាធារណៈ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ធ្វើការប៉ាន់ប្រមាណទៅលើកម្រិត ដែលរាជរដ្ឋាភិបាល ផ្តល់ឱកាសដល់សាធារណៈជនចូលរួមក្នុងដំណើរការថវិកា ។ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នសវនកម្មជាន់ខ្ពស់ គួរតែផ្តល់ឱកាសឱ្យសារធារណៈចូលរួមគ្រប់ដំណាក់កាលនៃដំណើការរៀបចំថវិកា ។

សំនួរសម្រាប់ធ្វើការប៉ាន់ប្រមាណទៅលើការចូលរួម នៅក្នុងការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៧ ត្រូវបានកែសម្រួល ដើម្បីបន្សុំនឹងគោលនយោបាយថ្មីនៃអង្គការផ្តួចផ្តើមជាសកលសម្រាប់តម្លាភាពសារពើពន្ធទៅលើការចូលរួមជាសាធារណៈ ដែលបច្ចុប្បន្នកំពុងត្រូវបានប្រើប្រាស់ជាគោលដោយមានការទទួលស្គាល់យ៉ាងទូលំទូលាយ អំពីការចូលរួមជាសាធារណៈនៅក្នុងដំណើរការថវិកាជាតិ។ យ៉ាងណាមិញ ទិន្នន័យស្តីពីវិសាលភាពនៃការចូលរួមជាសាធារណៈក្នុងដំណើរការថវិកានៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៧ មិនអាចប្រៀបធៀបដោយផ្ទាល់ទៅនឹងទិន្នន័យដែលបានមកពីការបោះពុម្ព ពីមុនៗនោះទេ។

**តើការចូលរួមជាសាធារណៈនៅក្នុងប្រទេសកម្ពុជាស្ថិតនៅកំរិតណាធៀបនឹងប្រទេសក្នុងតំបន់?**




ពិន្ទុនៃប្រទេសកម្ពុជា ៤ លើ ១០០ពិន្ទុ ដែលបង្ហាញថាការផ្តល់ឱកាសឲ្យសាធារណៈចូលរួម នៅក្នុងដំណើរការថវិកានៅមានកំរិត។ ពិន្ទុនេះទាបជាងពិន្ទុមធ្យមសកល ១២ពិន្ទុលើ១០០។

**តើមានស្ថាប័នណាផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ដែលអាចផ្តល់ឱកាសសម្រាប់ការចូលរួមជាសាធារណៈ?**



# ការត្រួតពិនិត្យថវិកា

ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ធ្វើការពិនិត្យមើលតួនាទីរបស់ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័នសវនកម្មជាន់ខ្ពស់ និងស្ថាប័នសារពើពន្ធឯករាជនៅក្នុងដំណើរការថវិកា និងវិសាលភាពដែលពួកគេអាចផ្តល់បន្ថែមដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យថវិកា។ ស្ថាប័នទាំងនេះមានតួនាទីសំខាន់ ដូចមានចែងនៅក្នុងច្បាប់ ឬរដ្ឋធម្មនុញ្ញជាតិ នៅក្នុងផែនការថវិកា និងការត្រួតពិនិត្យលើការអនុវត្តរបស់ខ្លួន។

សូចនាករទាំងនេះត្រូវបានកែសម្រួល ដើម្បីឱ្យមានភាពប្រសើរឡើងក្នុងការវាយតម្លៃអំពីតួនាទីរបស់ស្ថាប័នត្រួតពិនិត្យជាផ្លូវការ ធានាសុចរិតភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈ។ យ៉ាងណាមិញទិន្នន័យអំពីតួនាទី និងប្រសិទ្ធភាពនៃស្ថាប័នត្រួតពិនិត្យនៅក្នុងការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៧ មិនគួរប្រៀបធៀបដោយផ្ទាល់ទៅនឹងទិន្នន័យដែលបានមកពីការបោះពុម្ពផ្សាយមុននោះទេ។

### តើអង្គនិតិបញ្ញត្តិណាខ្លះនៅក្នុងប្រទេសកម្ពុជាដែលអាចផ្តល់ការត្រួតពិនិត្យថវិកា?




ស្ថាប័ននីតិបញ្ញត្តិ នៅមានកំរិតក្នុងការត្រួតពិនិត្យក្នុងដំណើរការនៃវដ្តថវិកា។ ពិន្ទុនេះឆ្លុះបញ្ចាំងថា ស្ថាប័ននីតិបញ្ញត្តិនៅមានកំរិតក្នុងការត្រួតពិនិត្យនៅក្នុងដំណាក់កាលរៀបចំផែនការនៃវដ្តថវិកា និងខ្សោយក្នុងការត្រួតពិនិត្យក្នុងដំណាក់កាលអនុវត្តន៍នៃវដ្តថវិកា។

ឧបសគ្គចំបងៗដែលជះឥទ្ធិពលដល់ការត្រួតពិនិត្យរបស់ស្ថាប័ននីតិបញ្ញត្តិមាន:

- គណកម្មការស្ថាប័ននីតិបញ្ញត្តិ មិនបានពិនិត្យ ឬមិនបានផ្សព្វផ្សាយរបាយការណ៍ នៃការវិភាគលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលនៅលើគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។
- គណកម្មការស្ថាប័ននីតិបញ្ញត្តិ មិនបានពិនិត្យ ឬមិនបានផ្សព្វផ្សាយរបាយការណ៍អនុវត្តន៍ក្នុងឆ្នាំនៅលើគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។
- គណកម្មការស្ថាប័ននីតិបញ្ញត្តិ មិនបានពិនិត្យ ឬមិនបានផ្សព្វផ្សាយរបាយការណ៍សវនកម្មនៅលើគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

### តើស្ថាប័នសវនកម្មជាន់ខ្ពស់នៅក្នុងប្រទេសកម្ពុជាមានសមត្ថភាពកំរិតណាក្នុងការត្រួតពិនិត្យថវិកា?




ស្ថាប័នសវនកម្មជាន់ខ្ពស់មានសមត្ថភាពខ្ពស់ក្នុងការត្រួតពិនិត្យថវិកា

- តាមច្បាប់ ស្ថាប័នសវនកម្មជាន់ខ្ពស់មានសិទ្ធិពេញលេញក្នុងការអនុវត្តសវនកម្មគ្រប់ពេលដែលសាកសម។
- ជាងនេះទៅទៀត ថ្នាក់ដឹកនាំនៃស្ថាប័នសវនកម្មជាន់ខ្ពស់មិនអាចផ្លាស់ចេញដោយគ្មានការយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ រឺតុលាការ ដែលជំរុញឱ្យស្ថាប័នសវនកម្មជាន់ខ្ពស់នេះមានភាពឯករាជ្យ។
- ជាចុងក្រោយស្ថាប័នសវនកម្មជាន់ខ្ពស់ ត្រូវបានផ្តល់ធនធានគ្រប់គ្រាន់ដើម្បីបំពេញកាតួកិច្ចក្នុងអាណត្តិរបស់ខ្លួន ប៉ុន្តែដំណើរការធ្វើសវនកម្មមិនបានត្រួតពិនិត្យដោយភ្នាក់ងារឯករាជ្យឡើយ។

**ការត្រួតពិនិត្យដោយ ស្ថាប័នសារពើពន្ធឯករាជ្យ**

ប្រទេសកម្ពុជា មិនមានស្ថាប័នសារពើពន្ធឯករាជ្យនោះទេ។ កំលុងពេលដែលស្ថាប័នសារពើពន្ធឯករាជ្យមិនទាន់ត្រូវបានបង្កើតឡើងជាសកលនៅឡើយ ពួកគេត្រូវបានទទួលស្គាល់ជាបន្តបន្ទាប់ ថាជាប្រភពសំខាន់នៃភាពឯករាជ្យ ឬព័ត៌មានឯករាជ្យ។ ស្ថាប័នសារពើពន្ធឯករាជ្យទទួលស្គាល់ដោយស្ថាប័នក្នុងទម្រង់ផ្សេងៗ ឧទាហរណ៍: រួមទាំងការិយាល័យថវិកាសភា និងក្រុមប្រឹក្សាសារពើពន្ធ។ ព័ត៌មានបន្ថែម សូមមើលលើ Lisa Von Tapp, Ian Lienert, and Joachim Wehner, "គោលការណ៍សម្រាប់ស្ថាប័នសារពើពន្ធឯករាជ្យ និងករណីសិក្សា" អង្គការសម្រាប់សហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច OECD Journal on Budgeting, ខែមីនា ឆ្នាំ២០១៦ (អនុម័តពិសេស) ទំព័រទី ៩ ដល់ ២៥។

# អនុសាសន៍

ព័ត៌មានបន្ថែមពីអនុសាសន៍ទៅលើការរកឃើញពីការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាសម្រាប់ប្រទេសកម្ពុជា សូមចូលទៅកាន់គេហទំព័រ Open Budget Survey Data Explorer at survey.internationalbudget.org។

### តើប្រទេសកម្ពុជាពង្រឹងតម្លាភាពថវិកាយ៉ាងដូចម្តេច?

ដើម្បីពង្រឹងលើតម្លាភាពថវិកា ប្រទេសកម្ពុជាគួរផ្តល់អាទិភាពទៅលើការអនុវត្តខាងក្រោម:

- ផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល និងរបាយការណ៍ចុងឆ្នាំឱ្យបានទាន់ពេលវេលា។
- ពង្រីកវិសាលភាពនៃរបាយការណ៍សវនកម្មទៅគ្រប់ការចំណាយរបស់រាជរដ្ឋាភិបាល រួមទាំងជំនួយផ្សេងៗពីខាងក្រៅ។
- រួមបញ្ចូលទាំងព័ត៌មានទំនាក់ទំនងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃរបាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ។

## ប្រទេសកម្ពុជាពង្រឹងការចូលរួមពីសាធារណៈជនក្នុងដំណើរការថវិកាយ៉ាងដូចម្តេច ?

ដើម្បីពង្រឹងលើការចូលរួមពីសាធារណៈជនក្នុងដំណើរការថវិកា ប្រទេសកម្ពុជាគួរមមើលលើការអនុវត្តខាងក្រោម:

- សាកល្បងយន្តការ ដើម្បីឱ្យសាធារណៈជន និងមន្ត្រីរដ្ឋាភិបាលធ្វើការផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាថវិកាជាតិ កំលុងពេលរៀបចំថវិកា។ យន្តការទាំងនេះអាចបង្កើតឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ដែលអាចបង្កើនការចូលរួមក្នុងដំណើរការរៀបចំថវិកា។ ឧទាហរណ៍ផ្សេងៗនៃយន្តការបែបនេះសូមមើលលើគេហទំព័រ www.fiscaltransparency.net/mechanisms/
- រៀបចំជាព្រឹត្តការណ៍ផ្សព្វផ្សាយទៅលើដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលមានការចូលរួមពីសាធារណៈជន ឬអង្គការសង្គមស៊ីវិល ដើម្បីជាសក្ខីកម្មនៅក្នុងការពិភាក្សារបស់ស្ថាប័ននីតិបញ្ញត្តិ។
- បង្កើតយន្តការផ្លូវការដើម្បីសាធារណៈជនអាច ជួយស្ថាប័នសវនកម្មជាន់ខ្ពស់ក្នុងការដំណើរការធ្វើសវនកម្ម និងចូលរួមស៊ើបអង្កេតលើសវនកម្ម ។

## ប្រទេសកម្ពុជាពង្រឹងការត្រួតពិនិត្យថវិកាយ៉ាងដូចម្តេច ?

ដើម្បីពង្រឹងលើការត្រួតពិនិត្យថវិកា ប្រទេសកម្ពុជាគួរមានការអនុវត្តដូចខាងក្រោម:

- ធានាថាគណៈកម្មាធិការនៃស្ថាប័ននីតិប្រតិបត្តិនឹងពិនិត្យ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីការវិភាគរបស់ខ្លួនលើសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលនៅលើគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- ធានាថាគណៈកម្មាធិការនៃស្ថាប័ននីតិប្រតិបត្តិនឹងពិនិត្យ និងផ្សព្វផ្សាយរបាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ នៅលើគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- ធានាថាដំណើរការសវនកម្មនឹងត្រូវបានត្រួតពិនិត្យដោយភ្នាក់ងារឯករាជ្យទេ
- ពិចារណាក្នុងការបង្កើតឱ្យមានស្ថាប័នសារពើពន្ធឯករាជ្យ ដើម្បីពង្រឹងការត្រួតពិនិត្យថវិកា។

# វិធីសាស្រ្ត

ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកា ប្រើប្រាស់លក្ខណៈវិនិច្ឆ័យទទួលស្គាល់ជាអន្តរជាតិ ដែលបង្កើតឡើងដោយអង្គការពហុភាគី រួមមាន មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អង្គការសម្រាប់សហប្រតិបត្តិការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) និងអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មជាន់ខ្ពស់ (INTOSAI) និងអង្គការផ្តួចផ្តើមជាសកលសម្រាប់តម្លាភាពសារពើពន្ធ (GIFT)។

ការអង្កេតនេះ ជាការស្រាវជ្រាវ ផ្អែកលើភាពជាក់ស្តែង ក្នុងការវាយតម្លៃពីអ្វីដែលបានកើតឡើងក្នុងការអនុវត្តតាមរយៈការអង្កេតដែលបានរៀបចំជាស្រេច។ ដំណើរការស្រាវជ្រាវទាំងមូល ត្រូវចំណាយពេលប្រហែល១៨ខែ ដែលចាប់ផ្តើមពីខែសីហា ឆ្នាំ២០១៦ ដល់ខែមករា ឆ្នាំ២០១៨ ដែលបានចូលរួមពីអ្នកជំនាញប្រហែល ៣០០នាក់ មកពី ១១៥ប្រទេស ។ ការអង្កេតនេះ ត្រូវបានកែសម្រួលបន្តិចបន្តួច ពីការអង្កេតឆ្នាំ២០១៥ ដើម្បីឆ្លុះបញ្ចាំងអំពី វិធីសាស្ត្រក្នុងការផ្សព្វផ្សាយព័ត៌មានថវិកា និងធ្វើការពង្រឹងនៃសំនួរនិមួយៗនៅក្នុងការចូលរួមក្នុងដំណើរការថវិកា និងការត្រួតពិនិត្យថវិកា។ ការពិភាក្សាលម្អិតទៅលើការផ្លាស់ប្តូរទាំងនេះ អាចស្វែងរកនៅក្នុងកំណត់ត្រាបច្ចេកទេសលើការប្រៀបធៀបសន្ទស្សន៍ នៃការផ្សព្វផ្សាយព័ត៌មានថវិកាពីនិមួយៗ នៅក្នុងអាស័យដ្ឋានខាងក្រោម។

ការឆ្លើយតបសំនួរនៃការអង្កេតនេះ ត្រូវបានគាំទ្រដោយអំណះអំណាងច្បាស់លាស់ ដូចជា ឯកសារយោងជាសាធារណៈ សេចក្តីថ្លែងការជាផ្លូវការរបស់រាជរដ្ឋាភិបាល ឬអនុសាសន៍ ដែលបានមកពីកិច្ចសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីរដ្ឋាភិបាល ឬភាគីដែលបានដឹងឮដទៃទៀត។



ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកា ត្រូវបានរៀបចំឡើងពីការបំពេញកម្រងសំនួរសម្រាប់ប្រទេសនីមួយៗ ដោយអ្នកជំនាញថវិកាឯករាជ្យដែលមិនជាប់ទាក់ទងនឹងរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ។

សេចក្តីព្រាងលទ្ធផលរបស់ប្រទេសនីមួយៗ ត្រូវបានត្រួតពិនិត្យដោយឡែកៗពីគ្នា ដោយអ្នកជំនាញអនាមិក ដែលមិនជាប់ទាក់ទងទៅនឹងរដ្ឋាភិបាល។

លើសពីនេះទៅទៀត ភាពជាដៃគូថវិកាអន្តរជាតិ (IBP) អញ្ជើញរដ្ឋាភិបាលប្រទេសនីមួយៗ ដើម្បីផ្តល់អនុសាសន៍ទៅលើសេចក្តីព្រាងលទ្ធផលនៃការអង្កេតនេះ និងការធ្វើការពិនិត្យលើអនុសាសន៍ទាំងនេះ មុនពេលចេញលទ្ធផលចុងក្រោយ។

ក្រុមអ្នកស្រាវជ្រាវធ្វើការឆ្លើយតបទៅនឹងធាតុចូលរបស់ក្រុមអ្នកពិនិត្យ និងរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ ហើយប្រសិនបើអាចទៅរួច ភាពជាដៃគូថវិកាអន្តរជាតិនឹងដាក់អំណះអំណាងទៅលើចម្លើយផ្ទុយគ្នាក្នុងការជ្រើសរើសចម្លើយ ដើម្បីធានាអោយមានភាពត្រឹមត្រូវនៅគ្រប់ប្រទេស។

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់អនុសាសន៍ទៅលើសេចក្តីព្រាងលទ្ធផលនៃកម្រងសំនួរ ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកាដែរ។


អ្នកជំនាញដែលបានបំពេញទៅលើការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកាប្រចាំប្រទេសកម្ពុជាមានឈ្មោះខាងក្រោម:
អ្នកស្រី គីម ណៃ និងលោក ស៊ុន យូ៉ា
បកប្រែ និងកែសម្រួលជាភាសាខ្មែរដោយ: កញ្ញា អ៊ុច សុវណ្ណាឡៃ
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពី កម្ពុជា
អាសយដ្ឋាន: ផ្ទះលេខ៩-១១ផ្លូវ៤៧៦ សង្កាត់ទួលទំពូង១
ប្រអប់សំបុត្រលេខ២២៩៥ ភ្នំពេញ។
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh និង/ ឬ www.cambodianbudget.org


**សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ:**

www.openbudgetsurvey.org
. The Open Budget Survey 2017: Global report
. Data explorer
. Methodology report
. Full questionnaire